# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

របាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
3ខែ និង 6ខែ ដែលបានបញ្ចប់
ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្ដីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00001157 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង2<br>ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ភាគហ៊ុនិក | Kookmin Bank<br>LOLC International Private Limited<br>The Bank of East Asia, Limited<br>ក្រុមហ៊ុន បុគ្គលិកប្រាសាក់លីមីតធីត | |
| ក្រុមប្រឹក្សាភិបាល | លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Ji Kyu Jang | អភិបាល |
| | លោក Ishara Chinthaka Nanayakkara | អភិបាល |
| | លោក ស៊ីម សេនាជាតិ | អភិបាល |
| | លោក Minki Brian Hong | អភិបាល |
| | លោក Hak Soo Kim | អភិបាល (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2021) |
| គណៈកម្មាធិការប្រតិបត្តិ | លោក ស៊ីម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| | លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| | លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| | លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងអាជីវកម្ម |
| | លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងទីផ្សារ |
| | លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ធនធានមនុស្ស |
| | លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ មក

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 6 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 7 – 8 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 9 |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | 10 – 11 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 12 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 13 – 14 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 15 – 63 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សាភិបាល" ឬ"អភិបាល") នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ("ក្រុមហ៊ុន") សូមធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021។

## ព័ត៌មានអំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាព ចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀតក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងទាំងនេះ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះដែរ។



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | អគារលេខ 212 ផ្លូវ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | ទូរស័ព្ទ៖ 023 220 102 | សេវាអតិថិជន៖ 023 / 086 999 911 | ទូរសារ៖ 023 216 362
ប្រអប់សំបុត្រ៖ 2412 | អ៊ីម៉ែល៖ info@prasac.com.kh | វេបសាយត៍៖ www.prasac.com.kh | ចុះបញ្ជីពាណិជ្ជកម្មលេខ៖ 00001157 | គ្រឹះស្ថានឯកជន

## ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទ ប្រាសាក់ ម.ក

### ដើមទុន

នៅថ្ងៃទី12 ខែឧសភា ឆ្នាំ2021 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនរបស់ខ្លួនពី 230,000,000 ដុល្លារអាមេរិកទៅ 300,000,000 ដុល្លារអាមេរិក តាមរយៈការធ្វើមូលធនកម្មលើប្រាក់ចំណេញរក្សាទុក។ សំណើរនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី31 ខែឧសភា ឆ្នាំ2021។ អនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុន ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ហើយទទួលបានការយល់ព្រមពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី9 ខែមិថុនា ឆ្នាំ2021។

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

### ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានទៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទានអាក្រក់ដែលលុបចេញពីបញ្ជី ឬចំនួននៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថាបណ្តាទ្រព្យសកម្ម (លើកលែងបំណុល) ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## ព្រឹត្តិការណ៍បន្ទាប់ពីគ្រានៃការិយបរិច្ឆេទ (ត)

### វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងបានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងការិយបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

### ការប្រែប្រួលនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងកាលបរិច្ឆេទរាយការណ៍ មកទល់នឹងការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ព្រឹត្តិការណ៍បន្តបន្ទាប់

ពុំមានព្រឹត្តិការណ៍ជាសារវន្តណាមួយបានកើតឡើង ក្រោយកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលតម្រូវឲ្យមានការបង្ហាញ ឬកែតម្រូវ ក្រៅអំពីអ្វីដែលបានបង្ហាញរួច នៅក្នុងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ នឹងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Ji Kyu Jang | អភិបាល |
| លោក Ishara Chinthaka Nanayakkara | អភិបាល |
| លោក ស៊ឹម សេនាជាតិ | អភិបាល |
| លោក Minki Brian Hong | អភិបាល |
| លោក Hak Soo Kim | អភិបាល (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2021) |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |

(*): អភិបាលឯករាជ្យទាំងនេះ ត្រូវបានតែងតាំងដោយក្រុមហ៊ុននៅថ្ងៃទី10 ខែមេសា ឆ្នាំ2020។ នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ក្រុមហ៊ុនបានដាក់លិខិតជូន ធនាគារជាតិនៃកម្ពុជា ដើម្បីស្នើសុំការអនុម័តលើការតែងតាំងអភិបាលឯករាជ្យទាំងនេះ។ យ៉ាងណាមិញ សំណើរនេះមិនទទួលបានការអនុម័តពី ធនាគារជាតិនៃកម្ពុជា នោះឡើយ ដូចដែលបានរៀបរាប់នៅក្នុងលិខិតចុះថ្ងៃទី28 ខែមករា ឆ្នាំ2021។ នៅថ្ងៃទី9 ខែមេសា ឆ្នាំ2021 ក្រុមហ៊ុនបានដាក់លិខិតមួយច្បាប់ទៀតជូនទៅ ធនាគារជាតិនៃកម្ពុជា ដើម្បីស្នើសុំការអនុម័តលើការតែងតាំងបុគ្គលដទៃទៀត រួមមាន លោក Kyung Cheon Lee លោក Jaehong Park និង លោក ចាន់ សុផល ជាអភិបាលឯករាជ្យ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅកំពុងរង់ចាំការអនុម័តពីធនាគារជាតិនៃកម្ពុជា ។

## គណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| លោក អ៊ុំ សួជន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគកម្មដោយផ្ទាល់ក្នុងមូលធនរបស់ក្រុមហ៊ុនឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃទៀតឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែនិង 6ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅទំព័រទី 9 ដល់ទី 63 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34")។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិ ភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ ស.គ.អ.ក 34 ឬប្រសិនបើមានវៀចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងមានភាពមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុន នឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្ដីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្ដីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវ ក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ (រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា) ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ថាត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។*

លោក ស៊ីម សេនាជាតិ
*អភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 30 JUL 2021

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

**ជូនចំពោះភាគទុនិករបស់**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

## *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 63 ហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល")។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## *ទំហំនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចព្រមព្រៀងត្រួតពិនិត្យលេខ 2410 "*ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*"។ ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ និងធ្វើការវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានទំហំតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ វាមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានស្វែងយល់អំពីបញ្ហាជាសារវន្តទាំងអស់ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មបានឡើយ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 ("របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល") នោះឡើយ។

## *ការទាញចំណាប់អារម្មណ៍*

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលបង្ហាញពីការរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបដែលបានដាក់បង្ហាញនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។ សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំមិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020 គឺត្រូវបានធ្វើការត្រួតពិនិត្យដោយសវនករឯករាជ្យផ្សេង ដោយបានបញ្ចេញសេចក្តីសន្និដ្ឋានមិនមានបញ្ហានៅថ្ងៃទី7 ខែកញ្ញា ឆ្នាំ2020។ លើសពីនេះទៀត របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដោយមិនរាប់បញ្ចូលការធ្វើចំណាត់ថ្នាក់ឡើងវិញដូចដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យតែមួយ ដោយបានបញ្ចេញមតិនៅថ្ងៃទី31 ខែមីនា ឆ្នាំ2021 ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

ជាផ្នែកមួយនៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ យើងខ្ញុំបានត្រួតពិនិត្យលើការធ្វើចំណាត់ថ្នាក់ឡើងវិញ ដែលត្រូវបានយកមកអនុវត្តដើម្បីរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដូចដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។ យើងខ្ញុំមិនត្រូវបានតម្រូវឲ្យធ្វើការត្រួតពិនិត្យឡើងវិញ ឬអនុវត្តនីតិវិធីណាមួយទៅលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ក្រៅពីការធ្វើចំណាត់ថ្នាក់ឡើងវិញដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះទេ។ ហេតុដូច្នេះហើយ យើងខ្ញុំមិនបញ្ចេញសេចក្តីសន្និដ្ឋាន ឬទម្រង់នៃការអះអាងណាមួយ លើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល នោះឡើយ។ យ៉ាងណាមិញ ជាការសន្និដ្ឋានរបស់យើងខ្ញុំ ការធ្វើចំណាត់ថ្នាក់ឡើងវិញដូចបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 គឺមានភាពសមស្រប ហើយត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

ព្រះរាជាណាចក្រកម្ពុជា
ខេ ភី អឹម ជី ខេមបូឌា
KPMG CAMBODIA LTD.
ស្នាក់ការរាជធានីភ្នំពេញ

**ខៃ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី30 ខែកក្កដា ឆ្នាំ2021

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក (ការរាយការណ៍ឡើងវិញ) | សមមូលពាន់រៀល (កំណត់សម្គាល់ 4) (ការរាយការណ៍ឡើងវិញ) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 171,201,528 | 697,646,227 | 160,578,086 | 649,538,358 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 329,578,177 | 1,343,031,071 | 438,355,399 | 1,773,147,589 |
| សមតុល្យនៅធនាគារផ្សេងៗ | 8 | 12,223,725 | 49,811,679 | 3,975,029 | 16,078,992 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 3,279,156,563 | 13,362,562,994 | 2,978,579,934 | 12,048,355,833 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 4,722,167 | 19,242,830 | 1,341,096 | 5,424,733 |
| ទ្រព្យនិងបរិក្ខារ | 11 | 5,174,718 | 21,086,976 | 5,662,803 | 22,906,039 |
| សិទ្ធប្រើប្រាស់ទ្រព្យសកម្ម | 12 | 14,057,768 | 57,285,405 | 15,322,179 | 61,978,214 |
| ទ្រព្យសកម្មអរូបី | 13 | 1,504,428 | 6,130,544 | 1,607,168 | 6,500,995 |
| ពន្ធពន្យារសុទ្ធជាទ្រព្យសកម្ម | 20(គ) | 12,807,557 | 52,190,795 | 10,904,851 | 44,110,122 |
| **ទ្រព្យសកម្មសរុប** | | 3,830,426,631 | 15,608,988,521 | 3,616,326,545 | 14,628,040,875 |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីធនាគារនានា និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 14 | 54,395,289 | 221,660,803 | 37,232,817 | 150,606,745 |
| ប្រាក់បញ្ញើរបស់អតិថិជន | 15 | 2,268,580,984 | 9,244,467,510 | 2,074,680,943 | 8,392,084,414 |
| ប្រាក់កម្ចី | 16 | 722,196,369 | 2,942,950,204 | 794,430,317 | 3,213,470,632 |
| មូលបត្របំណុលត្រូវសង | 17 | 30,640,009 | 124,858,037 | 30,666,038 | 124,044,124 |
| អនុបំណុល | 18 | 122,369,117 | 498,654,152 | 113,667,817 | 459,786,320 |
| បំណុលភតិសន្យា | 19 | 13,294,988 | 54,177,076 | 14,424,818 | 58,348,389 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20(ខ) | 16,591,294 | 67,609,523 | 24,076,695 | 97,390,231 |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 21 | 582,940 | 2,375,481 | 435,375 | 1,761,092 |
| បំណុលផ្សេងៗ | 22 | 14,461,950 | 58,932,444 | 7,873,601 | 31,848,716 |
| **បំណុលសរុប** | | 3,243,112,940 | 13,215,685,230 | 3,097,488,421 | 12,529,340,663 |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 23(ក) | 300,000,000 | 1,200,000,000 | 230,000,000 | 920,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 284,132,429 | 1,163,635,470 | 285,224,840 | 1,163,897,093 |
| ទុនបម្រុង | 23(ខ) | 3,181,262 | 12,892,203 | 3,151,952 | 12,773,175 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 23(គ) | - | - | 461,332 | 1,778,127 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 16,775,618 | - | 251,817 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | 587,313,691 | 2,393,303,291 | 518,838,124 | 2,098,700,212 |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | 3,830,426,631 | 15,608,988,521 | 3,616,326,545 | 14,628,040,875 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021* | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ចំណូលការប្រាក់ | 24 | 242,118,738 | 983,244,195 | 207,160,286 | 844,385,325 |
| ចំណាយការប្រាក់ | 25 | (101,559,125) | (412,431,607) | (98,363,700) | (400,930,443) |
| **ចំណូលការប្រាក់សុទ្ធ** | | **140,559,613** | **570,812,588** | **108,796,586** | **443,454,882** |
| ចំណូលកម្រៃជើងសា | 26 | 4,334,419 | 17,602,076 | 2,469,833 | 10,067,039 |
| ចំណាយកម្រៃជើងសា | | (77,888) | (316,303) | (62,286) | (253,878) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | | **4,256,531** | **17,285,773** | **2,407,547** | **9,813,161** |
| ចំណូលផ្សេងៗ | 27 | 5,155,014 | 20,934,512 | 4,602,130 | 18,758,283 |
| ចំណូលវិភាគទាន | | 755,704 | 3,068,914 | 258,016 | 1,051,673 |
| ខាតសុទ្ធពីការប្តូររូបិយប័ណ្ណ | | (592,778) | (2,407,271) | (39,665) | (161,675) |
| **ចំណូលផ្សេងៗសរុប** | | **5,317,940** | **21,596,155** | **4,820,481** | **19,648,281** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | **150,134,084** | **609,694,516** | **116,024,614** | **472,916,324** |
| ចំណាយលើបុគ្គលិក | 28 | (37,848,583) | (153,703,096) | (34,696,344) | (141,422,298) |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | (16,800,898) | (68,228,447) | (23,507,072) | (95,814,825) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (6,969,022) | (28,301,198) | (7,864,331) | (32,055,015) |
| ចំណាយរំលស់ | 30 | (3,255,332) | (13,219,903) | (3,196,425) | (13,028,627) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **85,260,249** | **346,241,872** | **46,760,442** | **190,595,559** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (16,784,682) | (68,162,594) | (9,386,929) | (38,261,123) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **68,475,567** | **278,079,278** | **37,373,513** | **152,334,436** |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 16,523,801 | - | 8,015,518 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | **68,475,567** | **294,603,079** | **37,373,513** | **160,349,954** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | កំណត់សម្គាល់ | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021* *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020* *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 24 | 123,300,397 | 500,969,513 | 102,980,927 | 420,986,030 |
| ចំណាយការប្រាក់ | 25 | (51,341,304) | (208,599,718) | (49,967,611) | (204,267,594) |
| **ចំណូលការប្រាក់សុទ្ធ** | | **71,959,093** | **292,369,795** | **53,013,316** | **216,718,436** |
| ចំណូលកម្រៃជើងសា | 26 | 2,160,569 | 8,778,392 | 520,855 | 2,129,255 |
| ចំណាយកម្រៃជើងសា | | (56,813) | (230,831) | (30,040) | (122,804) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | | **2,103,756** | **8,547,561** | **490,815** | **2,006,451** |
| ចំណូលផ្សេងៗ | 27 | 2,277,319 | 9,252,747 | 1,786,403 | 7,302,815 |
| ចំណូលវិភាគទាន | | 390,494 | 1,586,577 | 258,016 | 1,054,769 |
| ខាតពីការប្តូររូបិយប័ណ្ណសុទ្ធ | | (1,234,376) | (5,015,270) | (1,193,576) | (4,879,339) |
| **ចំណូលផ្សេងៗសុរុប** | | **1,433,437** | **5,824,054** | **850,843** | **3,478,245** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | **75,496,286** | **306,741,410** | **54,354,974** | **222,203,132** |
| ចំណាយលើបុគ្គលិក | 28 | (17,463,551) | (70,954,408) | (15,766,304) | (64,452,651) |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | 9 | (12,548,580) | (50,984,881) | (16,936,744) | (69,237,409) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (3,327,675) | (13,520,344) | (3,920,864) | (16,028,492) |
| ចំណាយរំលស់ | 30 | (1,643,832) | (6,678,889) | (1,615,848) | (6,605,587) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **40,512,648** | **164,602,888** | **16,115,214** | **65,878,993** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (8,001,136) | (32,508,616) | (3,223,934) | (13,179,442) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **32,511,512** | **132,094,272** | **12,891,280** | **52,699,551** |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 17,027,299 | - | 9,918,677 |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | **32,511,512** | **149,121,571** | **12,891,280** | **62,618,228** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុង | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 230,000,000 | 920,000,000 | 285,224,840 | 1,163,897,093 | 3,151,952 | 12,773,175 | 461,332 | 1,778,127 | - | 251,817 | 518,838,124 | 2,098,700,212 |
| មូលធនកម្មលើប្រាក់ចំណេញរក្សាទុក | 70,000,000 | 280,000,000 | (70,000,000) | (280,000,000) | - | - | - | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធ | | | | | | | | | | | | |
| សម្រាប់ការិយបរិច្ឆេទ | - | - | 68,475,567 | 278,079,278 | - | - | - | - | - | - | 68,475,567 | 278,079,278 |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 461,332 | 1,778,127 | - | - | (461,332) | (1,778,127) | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | - | (29,310) | (119,028) | 29,310 | 119,028 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 16,523,801 | - | 16,523,801 |
| **សមតុល្យនាថ្ងៃទី30 ខែមិថុនា ឆ្នាំ2021** | **300,000,000** | **1,200,000,000** | **284,132,429** | **1,163,635,470** | **3,181,262** | **12,892,203** | **-** | **-** | **-** | **16,775,618** | **587,313,691** | **2,393,303,291** |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2020 | | | | | | | | | | | | |
| (ការរាយការណ៍ឡើងវិញ) | 230,000,000 | 920,000,000 | 174,271,385 | 711,503,244 | 3,093,332 | 12,534,181 | 2,644,420 | 10,715,190 | - | 16,034,618 | 410,009,137 | 1,670,787,233 |
| ប្រាក់ចំណេញសុទ្ធ | | | | | | | | | | | | |
| សម្រាប់ការិយបរិច្ឆេទ | - | - | 37,373,513 | 152,334,436 | - | - | - | - | - | - | 37,373,513 | 152,334,436 |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 2,644,420 | 10,715,190 | - | - | (2,644,420) | (10,715,190) | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | - | (29,310) | (119,468) | 29,310 | 119,468 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 8,015,518 | - | 8,015,518 |
| **សមតុល្យនាថ្ងៃទី30 ខែមិថុនា ឆ្នាំ2020** | | | | | | | | | | | | |
| **(ការរាយការណ៍ឡើងវិញ)** | **230,000,000** | **920,000,000** | **214,260,008** | **874,433,402** | **3,122,642** | **12,653,649** | **-** | **-** | **-** | **24,050,136** | **447,382,650** | **1,831,137,187** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពប្រតិបត្តិការ** | 31 | **(46,222,301)** | **(187,708,764)** | **23,201,970** | **94,571,227** |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (538,317) | (2,186,105) | (2,058,017) | (8,388,477) |
| ការទិញទ្រព្យសកម្មអរូបី | | (43,735) | (177,608) | (415,007) | (1,691,569) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | (147,430) | (598,713) | 432 | 1,761 |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 62,059 | 252,022 | 5,731 | 23,360 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(667,423)** | **(2,710,404)** | **(2,466,861)** | **(10,054,925)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 77,761,365 | 315,788,903 | 199,879,283 | 814,707,958 |
| ការទូទាត់ប្រាក់កម្ចី | | (147,932,831) | (600,755,227) | (142,820,262) | (582,135,388) |
| សាច់ប្រាក់បានពីអនុបំណុល | | 17,296,512 | 70,241,135 | - | - |
| ការទូទាត់អនុបំណុល | | (8,571,209) | (34,807,680) | (10,366,570) | (42,254,139) |
| សាច់ប្រាក់បានពីការបោះផ្សាយមូលបត្របំណុល | | - | - | 30,535,399 | 124,462,286 |
| ការទូទាត់បំណុលភតិសន្យា | | (1,950,153) | (7,919,571) | (1,779,013) | (7,251,257) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | **(63,396,316)** | **(257,452,440)** | **75,448,837** | **307,529,460** |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(110,286,040)** | **(447,871,608)** | **96,183,946** | **392,045,762** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 417,065,787 | 1,687,031,108 | 430,322,406 | 1,753,563,804 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 10,967,970 | - | 9,380,934 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 6 | **306,779,747** | **1,250,127,470** | **526,506,352** | **2,154,990,500** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

| | កំណត់សម្គាល់ | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021* | | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | 31 | **28,322,146** | **115,072,880** | **206,486,654** | **844,117,439** |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យនិងបរិក្ខារ | | (128,856) | (523,542) | (1,042,228) | (4,260,628) |
| ការទិញទ្រព្យសកម្មអរូបី | | - | - | (338,200) | (1,382,561) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | (147,430) | (599,008) | 432 | 1,766 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(276,286)** | **(1,122,550)** | **(1,379,996)** | **(5,641,423)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 17,517,236 | 71,172,530 | 7,051,273 | 28,825,604 |
| ការទូទាត់ប្រាក់កម្ចី | | (99,992,458) | (406,269,357) | (72,293,463) | (295,535,677) |
| សាច់ប្រាក់បានពីអនុបំណុល | | 17,296,512 | 70,275,728 | - | - |
| ការទូទាត់អនុបំណុល | | (5,945,928) | (24,158,305) | (7,421,693) | (30,339,881) |
| សាច់ប្រាក់បានពីការបោះផ្សាយមូលបត្របំណុល | | - | - | 30,535,399 | 124,828,711 |
| ការទូទាត់បំណុលភតិសន្យា | | (987,668) | (4,012,895) | (932,299) | (3,811,238) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(72,112,306)** | **(292,992,299)** | **(43,060,783)** | **(176,032,481)** |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(44,066,446)** | **(179,041,969)** | **162,045,875** | **662,443,535** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 350,846,193 | 1,419,172,849 | 364,460,477 | 1,483,354,141 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 9,996,590 | - | 9,192,824 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 6 | **306,779,747** | **1,250,127,470** | **526,506,352** | **2,154,990,500** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នៅថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011។ ក្រុមហ៊ុនបានចុះបញ្ជីសារជាថ្មី នៅថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណជាមីក្រូហិរញ្ញវត្ថុឲ្យក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើនទៀតនៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 ក្រុមហ៊ុនមានបុគ្គលិកចំនួន 8,817 នាក់ (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020៖ ចំនួន 9,042 នាក់)។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 (*"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"*)។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុ តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុន ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត) សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ក) របាយការណ៍អនុលោមភាព (ត)

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី30 ខែកក្កដា ឆ្នាំ2021។

### (ខ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុន ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និង កាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត លុះត្រាតែមានការបង្ហាញផ្សេងពីនេះ។

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលទាក់ទង។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មាន អថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានធ្វើតេស្តលើរំញោចនៃការផ្លាស់ប្តូរនៅក្នុងប៉ារ៉ាម៉ែត្រជាមូលដ្ឋានក្នុងការប៉ាន់ស្មាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យធ្ងន់ធ្ងរ ដែលអាចបណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃយោងនៃទ្រព្យសម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ ត្រូវបានព័ណ៌នាដូចខាងក្រោម៖

#### *(i) ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ត) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(i) ការវិនិច្ឆ័យ (ត)*

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- ការកើនឡើងជាសារវន្តចំពោះហានិភ័យឥណទាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូងដែរ ឬទេ ការកំណត់វិធីសាស្ត្រសម្រាប់ការដាក់បញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត ទៅក្នុងការវាស់វែងលើ ការខាតបង់រំពឹងទុកលើឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើម៉ូឌែលសម្រាប់ការវាស់វែង ECL។

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន*

- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលធាតុចូលទៅក្នុងគំរូនៃការវាស់វែង ECL រួមទាំងការបញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត។
- ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយធាតុចូលមិនអាចអង្កេតបានជាសារវន្ត។
- ការវាស់វែងនៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់៖ ការសន្មតដែលគណនាដោយផ្អែកលើមូលដ្ឋាននៃការគណនាតម្លៃ (Acturial) ។
- ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗអំពីលទ្ធភាព និងទំហំនៃលំហូរធនធាន។
- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលប្រើក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

**វីរុសកូរ៉ូណា និងផលប៉ះពាល់លើ ECL**

ECL ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍ នាកាលបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃវីរុសណូវែលកូរ៉ូណា ("ជំងឺកូវីដ-19") បានរាតត្បាតក្នុងប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ដែលបានធ្វើឲ្យមានការរាំងស្ទះលើសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (GDP) និងសូចនាករសំខាន់ៗផ្សេងទៀត នឹងត្រូវយកមកពិចារណា សម្រាប់ការកំណត់នូវភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេណារីយ៉ូសេដ្ឋកិច្ចនានា ដែលត្រូវបានយកមកប្រើក្នុងការប៉ានស្មាន ECL។ ការប៉ានស្មានរបស់អ្នកគ្រប់គ្រង ត្រូវបានកំណត់ដោយផ្អែកទៅលើសេណារីយ៉ូដែលអាចកើតឡើងនាពេលអនាគត ដោយគិតពីស្ថានភាពជាក់ស្តែង កាលៈទេសៈ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងព័ត៌មានគាំទ្រដែលអាចប្រើប្រាស់បាន នាកាលបរិច្ឆេទរាយការណ៍នេះ។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)*

**វីរុសកូវ៉ីណា និងផលប៉ះពាល់លើ ECL (ត)**

ការគណនា ECL នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនប្រាកដប្រជាជាសារវន្ត។ អ្នកគ្រប់គ្រងបានធ្វើការព្យាករណ៍ដ៏ប្រសើរបំផុត លើផលប៉ះពាល់របស់វីរុសកូវ៉ីណាមកលើក្រុមហ៊ុន យ៉ាងណាមិញ ការព្យាករណ៍នេះអាចនឹងប្រែប្រួលជាសារវន្តនៅពេលមានព្រឹត្តិការណ៍ថ្មីៗកើតឡើងជាក់ស្តែង។ ជាលទ្ធផល តួលេខនេះ មិនគួរត្រូវបានយកជាការណែនាំជាក់លាក់ ឬជាការព្យាករណ៍នៃផលប៉ះពាល់ហិរញ្ញវត្ថុចុងក្រោយ ដែលបានរំពឹងទុកនោះទេ។ ក្នុងករណីដែលផលប៉ះពាល់នោះមានសភាពកាន់តែធ្ងន់ធ្ងរ និងមានរយៈពេលយូរជាងការរំពឹងទុក នោះផលប៉ះពាល់ទន្ទឹមគ្នានឹងកើតមានឡើងចំពោះ ECL មកលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ។

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល (ត)

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021 | 1 ដុល្លារអាមេរិក= | 4,075រៀល | 4,061រៀល |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2020 | 1 ដុល្លារអាមេរិក= | 4,093រៀល | 4,076រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | 1 ដុល្លារអាមេរិក= | 4,045រៀល | 4,077រៀល |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 5. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ជាទូទៅពាក់ព័ន្ធនឹងការផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដល់ប្រជាពលរដ្ឋ សហគ្រាសធនតូច និងមធ្យម ព្រមទាំងចូលរួមក្នុងរាល់សកម្មភាពផ្សេងៗទៀត ដែលគាំទ្រដល់កម្មវត្ថុទាំងនេះ។ ពុំមានបច្ច័យដែលនាំឲ្យមានបម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម ដែលមានលក្ខណៈជាសារវន្ត ដែលពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ចទាំងនេះទេ។

## 6. សាច់ប្រាក់ក្នុងដៃ

| | *ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ទីស្នាក់ការកណ្តាល | 29,464,085 | 120,066,147 | 43,578,608 | 176,275,469 |
| សាខានានា | 141,737,443 | 577,580,080 | 116,999,478 | 473,262,889 |
| | 171,201,528 | 697,646,227 | 160,578,086 | 649,538,358 |

